**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ ០៩ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងថ្នាក់ដឹកនាំក្រុមប្រតិបត្តិការសន្តិសុខ ថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យច្រកទ្វារ និងថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិសៀមរាប

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញសេចក្ដីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ
- បានឃើញសេចក្ដីសំរេចលេខ ៥១សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការកែតម្រូវសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ
- ដោយបានការឯកភាពពីក្រសួង ស្ថាប័នសាមី

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

- លោក **ម៉ិន រដ្ឋា** នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប ប្រធាន
- លោក **ទ្រាត់ សុខា** នាយកការិយាល័យទី៣ បញ្ជាការដ្ឋានកងទ័ពជើងអាកាស អនុប្រធាន
- លោក **អាន វណ្ណៈ** នាយរងខុទ្ទកាល័យសាលាខេត្តសៀមរាប អនុប្រធាន
- លោក **សុខ ផល** ប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- លោក **ជួន ណេឝន** ប្រធានការិយាល័យសន្តិសុខនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- លោក **សុខ សំអឿន** នាយរងការិយាល័យទីបញ្ជាការដ្ឋានកងទ័ពជើងអាកាស សមាជិក
- លោក **ឝុំ សមម្ឫទ្ធី** ប្រធានសាខាគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- លោក **ស៊ុំ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- លោក **ខាំន់ ណារុំខ** នាយរងការិយាល័យប្រតិបត្តិការទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងក្រុមហ៊ុនសេវាកម្ម គ្រប់គ្រងចរាចរដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ប្រការ ២.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចតទៅ :

- លោក **ម៉ិន រដ្ឋា** នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប ប្រធាន
- លោក **ពិន ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- លោក **ឝុំ សមម្ឫទ្ធី** ប្រធានសាខាគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

Decision to create Siem Reap Security Team.doc

- លោក **ស៊ឹ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងក្រុមហ៊ុនសម្បទាន អាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ប្រការ ៣.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំសមត្ថកិច្ច នៅបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

- លោក **ជួន ណេត** ប្រធានការិយាល័យសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- លោក **ឡុង ខៀម** នាយការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- លោក **គុំ សម្បត្តិ** ប្រធានសាខាគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- លោក **ស៊ឹ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- កម្លាំងសន្តិសុខក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក

**ប្រការ ៤.-**

ក្រុមប្រតិបត្តិការសន្តិសុខ និងក្រុមត្រួតពិនិត្យច្រកទ្វារ និងសមត្ថកិច្ចត្រួតពិនិត្យនៅបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិសៀមរាប ត្រូវអនុវត្តការងារស្របតាមតួនាទី ភារកិច្ច ដូចមានខ្លឹមសារ និងបទប្បញ្ញត្តិ ដែលចែងក្នុងអនុក្រឹត្យលេខ ០៦ អនក្រ. បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៥.-**

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ប្រការ ២ ប្រការ ៣ និងប្រការ ៥ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ**

**សុខ អាន**

**កន្លែងទទួល**
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

Decision to create Siem Reap Security Team